# ការទើបឡើងវិញប្រចាំថ្ងៃ ម្តងមួយជំហានៗ កំណែលើកទី១ (ថ្ងៃទី ១ ខែវិច្ឆិកា ~)
# ការឆ្លើយតបតាមក្រោយ(ថ្ងៃទី២៩ ខែវិច្ឆិកា ~)

## □ ការរៀបចំឡើងវិញលើកទីពីរ គឺត្រូវបានបម្រុងទុក ដោយពិចារណាលើនិន្នាការរីករាលដាល ដូចជាការកើនឡើងយ៉ាងឆាប់រហ័សនៃចំនួនអ្នកបានឆ្លង

◦ ការលើកកម្ពស់ផែនការឆ្លើយតបតាមក្រោយ សម្រាប់ផ្នែកវេជ្ជសាស្ត្រ និងការពារការរីករាលដាល ខណៈពេលដែលរក្សាកម្រិតបច្ចុប្បន្នរយៈពេល ៤សប្តាហ៍ មុនពេលប្រសិទ្ធភាពនៃការចាក់វ៉ាក់សាំងបន្ថែមលេចឡើង។

## □ ការផ្លាស់ប្តូរទៅជាការព្យាបាលនៅផ្ទះ

◦ ប្រព័ន្ធដែលអ្នកជំងឺត្រូវបានបញ្ជូនទៅស្ថាប័នវេជ្ជសាស្ត្រ មានតែនៅក្នុងករណីពិសេស ដែលមិនអាចព្យាបាលនៅផ្ទះបាន

| < បច្ចុប្បន្ន > | | < ផ្លាស់ប្តូរ > |
|---|---|---|
| ◦ (អ្នកជំងឺ) **អ្នកជំងឺ<u>ដែលមានអាយុក្រោម ៧០ឆ្នាំ ដែលគ្មានរោគសញ្ញា, អាការៈស្រាល និងយល់ព្រមទទួលការព្យាបាលនៅផ្ទះ ដោយគ្មានកត្តាចូលសម្រាន្តមន្ទីរពេទ្យ</u>**<br><br>◦(ហេតុផលដែលលើកលែង) បរិយាកាសលំនៅដ្ឋានងាយនឹងឆ្លងមេរោគ,ករណីមានជំងឺរ៉ាំរ៉ៃប្រចាំកាយ, អ្នកដែលមានអាយុលើសពី ៦០ឆ្នាំ ដែលមិនទាន់បានចាក់វ៉ាក់សាំង, ករណីមានអ្នករស់នៅជាមួយ ចង់ឱ្យចូលសម្រាន្តក្នុងមន្ទីរពេទ្យ។ល។ | ➔ | ◦ (អ្នកជំងឺ) **<u>ករណីអ្នកឆ្លង ជំងឺកូវីដ-១៩ ទាំងអស់</u>**<br><br>– ប៉ុន្តែ **ករណីដែលមានកត្តាចូលសម្រាន្តក្នុងមន្ទីរពេទ្យ, ករណីបរិយាកាសលំនៅដ្ឋានងាយនឹងឆ្លងមេរោគ, អ្នកដែលត្រូវការមើលថែទាំដោយគ្មានអាណាព្យាបាល**(កុមារ, ជនពិការ,អ្នកដែលមានអាយុចាប់ពី៧០ឆ្នាំឡើង ដែលបានចាក់វ៉ាក់សាំង។ល។) **ត្រូវការសម្រាកព្យាបាលក្នុងមន្ទីរពេទ្យ** |

◦ បង្កើតបណ្តាញទូរស័ព្ទបន្ទាន់សម្រាប់ការប្រឹក្សា និងការព្យាបាល ២៤ម៉ោង ក្នុងករណីមានអាសន្ន និងកំណត់ជាមុនបញ្ជូនទៅស្ថាប័នវេជ្ជសាស្ត្រ។

## □ លើកទឹកចិត្តដល់អ្នកដែលមិនទាន់បានចាក់វ៉ាក់សាំង ឱ្យចាក់វ៉ាក់សាំង និងអនុវត្តការចាក់វ៉ាក់សាំងបន្ថែមឱ្យបានឆាប់រហ័ស(ចាក់វ៉ាក់សាំងបន្ថែម)

### ◦ ការលើកទឹកចិត្តដល់អ្នកដែលមិនបានទទួលការចាក់វ៉ាក់សាំងមូលដ្ឋាន

- ការបន្តការកក់ទុកជាមុន សម្រាប់កុមារ និង យុវវ័យ(អាយុ១២~១៧ឆ្នាំ)(~២២.០១.២០២២), យោងតាមលក្ខខណ្ឌក្នុងតំបន់ ការចាក់វ៉ាក់សាំងនឹងត្រូវបានអនុវត្តតាមរយៈសាលារៀន-ស្ថាប័នសម្រាប់ការចាក់វ៉ាក់សាំង(ទទួលបន្ទុកដោយក្រសួងអប់រំ)
- កិច្ចសហប្រតិបត្តិការជាមួយសហគមន៍វេជ្ជសាស្ត្រ និងការលើកទឹកចិត្តយ៉ាងសកម្មដល់មនុស្សចាស់ដែលមកពិនិត្យនៅស្ថាប័នវេជ្ជសាស្ត្រជាញឹកញាប់ ដើម្បីធ្វើការចាក់វ៉ាក់សាំង សម្រាប់ការព្យាបាលផ្នែកវេជ្ជសាស្ត្រផ្សេងៗ

◦ **ការអនុវត្តយ៉ាងឆាប់រហ័សនៃការចាក់វ៉ាក់សាំងបន្ថែម**

- នៅក្នុងកំឡុងខែធ្នូ គឺជាប្រតិបត្តិការនៃរយៈពេលចាក់វ៉ាក់សាំងយ៉ាងយកចិត្តទុកដាក់ សម្រាប់មនុស្សចាស់ (អាយុលើសពី ៦០ឆ្នាំ) ស្រដៀងគ្នាទៅនឹងការចាក់វ៉ាក់សាំងជំងឺគ្រុនផ្តាសាយដែរ ការចាក់វ៉ាក់សាំងត្រូវបានអនុវត្តនៅថ្ងៃតែមួយដោយគ្មានការកក់ទុកជាមុន
- សម្រាប់អ្នកដែលមានអាយុលើសពី ១៨ឆ្នាំទាំងអស់ ដែលបានបញ្ចប់ការចាក់វ៉ាក់សាំងជាមូលដ្ឋាន សម្រាប់ការចាក់វ៉ាក់សាំងបន្ថែមត្រូវអនុវត្ត ៥ខែ(១៥០ថ្ងៃ) បន្ទាប់ពីការចាក់វ៉ាក់សាំងជាមូលដ្ឋាន
- ប័ណ្ណចាក់ថ្នាំវ៉ាក់សាំង(វិញ្ញាបនបត្រចាក់ថ្នាំវ៉ាក់សាំង) កំណត់សុពលភាពរយៈពេល(៦ខែ), ដើម្បីប្រើប្រាស់ទីកន្លែងដែលតម្រូវឱ្យមានប័ណ្ណចាក់ថ្នាំវ៉ាក់សាំង គឺត្រូវបានទាមទារចាក់វ៉ាក់សាំងបន្ថែម ក្នុងរយៈពេល ៦ខែ
- សម្រាប់ហេតុផលដោយ បញ្ហាផ្ទាល់ខ្លួន(ការព្យាបាលជម្ងឺ, ការចេញដំណើរទៅក្រៅប្រទេសជាដើម), ការចាក់វ៉ាក់សាំងជាក្រុម(កន្លែងងាយស្រួលនឹងឆ្លងមេរោគ, ស្ថាប័នវេជ្ជសាស្រ្តជាដើម) និងអ្នកដែលមានបំណងចង់ទទួលវ៉ាក់សាំងដែលនៅសល់ សម្រាប់ការចាក់វ៉ាក់សាំងដំបូង គឺអាចធ្វើទៅបានក្នុងរយៈពេល១ខែ បើប្រៀបធៀបទៅនឹង*ស្តង់ដារសម្រាប់ការចាក់វ៉ាក់សាំងដោយក្រុមគោលដៅនីមួយៗ

  * (បញ្ចប់ការចាក់វ៉ាក់សាំងជាមូលដ្ឋានបាន ៤ខែ) ចាប់ពីអាយុ ៦០ឆ្នាំឡើង, អ្នកដែលមានជំងឺប្រចាំកាយ, ស្ថាប័នវេជ្ជសាស្រ្ត, កន្លែងងាយស្រួលនឹងឆ្លងមេរោគ
  (បញ្ចប់ការចាក់វ៉ាក់សាំងជាមូលដ្ឋានបាន ៥ខែ) អាយុចាប់ពី១៨~៤៩ឆ្នាំ, អាយុខ្ទង់៥០ឆ្នាំ
  (បញ្ចប់ការចាក់វ៉ាក់សាំងជាមូលដ្ឋានបាន ២ខែ) អ្នកចាក់វ៉ាក់សាំងJanssen, មនុស្សដែលមានប្រព័ន្ធភាពស៊ាំខ្សោយ

□ **ពង្រឹងការការពារជំងឺរាតត្បាត**

◦ មន្ទីរពេទ្យគិលានុបដ្ឋាយិកា•ការពង្រឹងការធ្វើតេស្តPCR សម្រាប់កន្លែងងាយស្រួលនឹងឆ្លងមេរោគផ្សេងៗ*, ដំណើរការដោយផ្អែកលើអ្នកដែលបានបញ្ចប់ការចាក់វ៉ាក់សាំងបន្ថែម

  * (បច្ចុប្បន្ន) ការធ្វើតេស្តPCR ១ដង(ពេលចូលសំរាក់នៅពេទ្យ)+រង់ចាំរយៈពេល១ថ្ងៃ នៅក្នុងបន្ទប់ចត្តាឡីស័ក → (ផ្លាស់ប្តូរ) **ការធ្វើតេស្តPCR ២ដង**(①ពេលចូលសំរាក់នៅពេទ្យ, ថ្ងៃទី៣ នៃការចត្តាឡីស័ក) + **រង់ចាំរយៈពេល ៤ថ្ងៃ នៅក្នុងបន្ទប់ចត្តាឡីស័ក**

- ត្រូវបានហាមឃាត់មិនឱ្យរៀបចំកម្មវិធីធ្វើគីមឈីនៅរដូវរងា នៅកន្លែងកម្សាន្ត និងសុខុមាលភាពសម្រាប់មនុស្សចាស់(សោធនិវត្តន៍ជនវ័យចាស់,មជ្ឍមណ្ឌលសុខុមាលភាពមនុស្សចាស់។ល។)

<បកប្រែដោយ មជ្ឈមណ្ឌលប្រឹក្សាតាមទូរស័ព្ទជានូរី ១៥៧៧- ១៣៦៦>